# ប្រទេសកម្ពុជាក្រោមការពិនិត្យឡើងវិញនៃអនុសញ្ញា ស៊ី-ដ៖ ស្ត្រីក្នុងការទទួលបានយុត្តិធម៌នៅកម្ពុជា

ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា តែងរងការរិះគន់ថាគ្មានប្រសិទ្ធិភាព កំសោយ និងខ្វះឯករាជ្យភាព។ នៅឆ្នាំ២០១៩ កម្ពុជាត្រូវបានចាត់ចំណាត់ថ្នាក់លេខ១២៥ ក្នុងចំណោមប្រទេសចំនួន ១២៦ នៅក្នុងការវាស់សន្ទស្សន៍នីតិរដ្ឋរបស់គម្រោងយុត្តិធម៌ពិភពលោក ដែលបានវាស់ស្ទង់អំពីការប្រកាន់ខ្ជាប់នីតិរដ្ឋរបស់ប្រទេសនានា។ នេះបង្កើតឱ្យមានឧបសគ្គចំពោះការបំពេញសិទ្ធិរបស់ស្ត្រី និងជាពិសេសការទទួលបាននូវយុត្តិធម៌របស់ស្ត្រី។ មានឧបសគ្គផ្សេងៗជាច្រើនទៀតចំពោះលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ ៖



## ១.ឧបសគ្គផ្នែកច្បាប់



- ច្បាប់បានបង្កើតឡើងដើម្បីការពារស្ត្រីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រមានលក្ខណៈមិនទាន់គ្រប់គ្រាន់ និងច្បាស់លាស់នៅឡើយទេ។
- ច្បាប់មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការដោះស្រាយភាពស្មុគស្មាញ និងវិធីផ្សេងៗ ដែលស្ត្រីទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- លើសពីនេះទៀត មិនមានច្បាប់ច្បាស់លាស់ក្នុងប្រទេសកម្ពុជា ក្នុងការទប់ស្កាត់ការរើសអើងទៅលើយេនឌ័រនៅឡើយនោះទេ។

## ២. ឧបសគ្គផ្នែកស្ថាប័ន

- ចំនួនតំណាងស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌មានចំនួនតិចតួចនៅឡើយ។ ឧទាហរណ៍៖ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៧ ចៅក្រមជាស្ត្រីមានប្រហែល ១៤% និងព្រះរាជអាជ្ញាជាស្ត្រីបានកើនឡើងពីចំនួន១៥នាក់ ដល់ ២៣នាក់។
- លើសពីនេះទៀត ឥរិយាបថរើសអើង និងផ្នត់គំនិតប្រកាន់លើយេនឌ័រមានវិសាលភាពយ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធយុត្តិធម៌។ មេធាវី និងព្រះរាជអាជ្ញាជាស្ត្រីមួយចំនួនមានអារម្មណ៍ថាពួកគេមិនត្រូវបានយកចិត្តទុកដាក់ពីសំណាក់ចៅក្រមនោះទេ។
- អំពើពុករលួយគឺជាបញ្ហាសំខាន់នៅក្នុងប្រព័ន្ធយុត្តិធម៌ដែលជារឿយៗបានរារាំងស្ត្រីពីការស្វែងរកយុត្តិធម៌។



## ៣. ឧបសគ្គផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងការអនុវត្តជាក់ស្តែង



- ការឈានទៅរកការទទួលបានសេវាយុត្តិធម៌អាចជាឧបសគ្គសម្រាប់ស្ត្រី ដោយសារតែឧបសគ្គផ្នែកសេដ្ឋកិច្ចនយោបាយ និងសង្គមដែលពួកគេជួបប្រទះ ជាពិសេសធ្វើឱ្យស្ត្រីទាំងនោះដកខ្លួនឯងចេញពីប្រព័ន្ធយុត្តិធម៌តែម្តង។
- ឧទាហរណ៍៖ ការប្រកាន់ឥរិយាបថជាគ្រួសារ និងចំណងអាពាហ៍ពិពាហ៍បានក្លាយជាសម្ពាធជំរុញអោយស្ត្រីស្វែងរកដំណោះស្រាយតាមរយៈការសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ នៅពេលមានករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង ដែលផ្ទុយទៅនឹងការទទួលបានយុត្តិធម៌ក្នុងព្រហ្មទណ្ឌ។

## ៤. ឧបសគ្គខាងកត្តាផ្សេងៗ

- ស្ត្រីជាច្រើនទទួលការរើសអើងដោយផ្អែកលើយេនឌ័រ ពាក់ព័ន្ធនឹងទម្រង់នៃការរើសអើងផ្សេងទៀតដោយផ្អែកលើកត្តាកំណត់ផ្សេងទៀតដែលបង្ហាញពីស្ថានភាពដែលត្រូវបានគេផាត់ចោល និងមើលរំលង។



- ឧទាហរណ៍៖ ស្ត្រីជនបទមិនត្រឹមតែជួបប្រទះនឹងបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច និងការរស់នៅប្រចាំថ្ងៃដូចជាការចំណាយថវិកា និងពេលវេលាច្រើនក្នុងការធ្វើដំណើរដើម្បីដំណើរការបណ្តឹងនៅតុលាការប៉ុណ្ណោះទេ ថែមទាំងត្រូវមានកាតព្វកិច្ចសម្រាប់គ្រួសារដែលសង្គមបានកំណត់ឱ្យដូចជាការថែទាំកូនចៅជាដើម។



- អ្នកស្រឡាញ់ភេទដូចគ្នាតែងតែយល់ឃើញថាពួកគេស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់នៅពេលដែលព្យាយាមប្រើប្រាស់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ដោយសារតែមានមេធាវីមួយចំនួនតូចប៉ុណ្ណោះដែលផ្តល់សេវាគាំទ្រ និង/ឬ អង្គការសង្គមស៊ីវិលមួយចំនួនតូចដែលផ្តល់ការប្រឹក្សាផ្នែកច្បាប់ដោយឥតគិតថ្លៃទៅក្រុមអ្នកស្រលាញ់ភេទដូចគ្នា។

## ៥. ស្ត្រី និងកុមារីដែលជាប់ពន្ធនាគារ



- ទោះបីជាពុំដឹងអំពីតួលេខជាក់លាក់យ៉ាងណាក៏ដោយ ប៉ុន្តែគិតត្រឹមខែកុម្ភៈ ឆ្នាំ២០២០ នេះ មានពន្ធនាគារចំនួន១៨ ក្នុងចំណោមពន្ធនាគារចំនួន២៨ មានកុមារចំនួន១០៣នាក់កំពុងរស់នៅជាមួយម្តាយរបស់ពួកគេ និងស្ត្រីមានផ្ទៃពោះចំនួន៤៣នាក់ស្ថិតក្នុងការឃុំខ្លួន។
- ប្រព័ន្ធពន្ធនាគារកម្ពុជា មិនមានលទ្ធភាពក្នុងការផ្តល់នូវតម្រូវការចាំបាច់បំផុតសម្រាប់កុមារទេ ដូចជាការអប់រំ ការថែទាំសុខភាព អាហារូបត្ថម្ភ និងប្រព័ន្ធទំនាក់ទំនងសង្គម និងភាពខុសពីស្តង់ដារអន្តរជាតិ។ តុលាការកម្ពុជាមិនបានគិតពីស្ថានភាពជាក់លាក់របស់ស្ត្រីនោះទេ នៅពេលធ្វើការសំរេចចិត្តទាក់ទងនឹងការឃុំឃាំង ដូចជាការមានផ្ទៃពោះជាដើម។

## ការដាក់របាយការណ៍របស់អង្គការសង្គមស៊ីវិលទៅកាន់ក្រុមការងារមុនវគ្គ

របាយការណ៍ស្តីពី "ការទទួលបានយុត្តិធម៌" របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) និងអង្គការទិសដៅយុត្តិធម៌ អាចស្វែងរកតាមរយៈ៖
https://bit.ly/2pkZbIJ




ឧបត្ថម្ភដោយ

EUROPEAN UNION

DCA actalliance

ផលិតដោយ

VOICES for GENDER EQUALITY

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

@CCHRCambodia @CCHRCambodia @EU.Cambodia



CC BY NC SA


ខែមិថុនា ឆ្នាំ២០២០

# ប្រទេសកម្ពុជាក្រោមការពិនិត្យឡើងវិញនៃអនុសញ្ញា ស៊ីដ:  ស្ត្រីក្នុងការទទួលបានយុត្តិធម៌នៅកម្ពុជា

ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា តែងរងការរិះគន់ថាគ្មានប្រសិទ្ធិភាព កំសោយ និងខ្វះឯករាជ្យភាព។ នៅឆ្នាំ២០១៩ កម្ពុជាត្រូវបានចាត់ចំណាត់ថ្នាក់លេខ១២៥ ក្នុងចំណោមប្រទេសចំនួន ១២៦ នៅក្នុងការវាស់សន្ទស្សន៍នីតិរដ្ឋរបស់គម្រោងយុត្តិធម៌ពិភពលោក ដែលបានវាស់ស្ទង់អំពីការប្រកាន់ខ្ជាប់នីតិរដ្ឋរបស់ប្រទេសនានា។ នេះបង្កើតឱ្យមានឧបសគ្គចំពោះការបំពេញសិទ្ធិរបស់ស្ត្រី និងជាពិសេសការទទួលបាននូវយុត្តិធម៌របស់ស្ត្រី។ មានឧបសគ្គផ្សេងៗជាច្រើនទៀតចំពោះលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ ៖



## ១.ឧបសគ្គផ្នែកច្បាប់



- ច្បាប់បានបង្កើតឡើងដើម្បីការពារស្ត្រីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រមានលក្ខណៈមិនទាន់គ្រប់គ្រាន់ និងច្បាស់លាស់នៅឡើយទេ។
- ច្បាប់មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការដោះស្រាយភាពស្មុគស្មាញ និងវិធីផ្សេងៗ ដែលស្ត្រីទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- លើសពីនេះទៀត មិនមានច្បាប់ច្បាស់លាស់ក្នុងប្រទេសកម្ពុជា ក្នុងការទប់ស្កាត់ការរើសអើងទៅលើយេនឌ័រនៅឡើយនោះទេ។

## ២. ឧបសគ្គផ្នែកស្ថាប័ន

- ចំនួនតំណាងស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌មានចំនួនតិចតួចនៅឡើយ។ ឧទាហរណ៍៖ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៧ ចៅក្រមជាស្ត្រីមានប្រហែល ១៤% និងព្រះរាជអាជ្ញាជាស្ត្រីបានកើនឡើងពីចំនួន១៥នាក់ ដល់ ២៣នាក់។
- លើសពីនេះទៀត ឥរិយាបថរើសអើង និងផ្នត់គំនិតប្រកាន់លើយេនឌ័រមានវិសាលភាពយ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធយុត្តិធម៌។ មេធាវី និងព្រះរាជអាជ្ញាជាស្ត្រីមួយចំនួនមានអារម្មណ៍ថាពួកគេមិនត្រូវបានយកចិត្តទុកដាក់ពីសំណាក់ចៅក្រមនោះទេ។
- អំពើពុករលួយគឺជាបញ្ហាសំខាន់នៅក្នុងប្រព័ន្ធយុត្តិធម៌ដែលជារឿយៗបានរារាំងស្ត្រីពីការស្វែងរកយុត្តិធម៌។



## ៣. ឧបសគ្គផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងការអនុវត្តជាក់ស្តែង



- ការឈានទៅរកការទទួលបានសេវាយុត្តិធម៌អាចជាឧបសគ្គសម្រាប់ស្ត្រី ដោយសារតែឧបសគ្គផ្នែកសេដ្ឋកិច្ចនយោបាយ និងសង្គមដែលពួកគេជួបប្រទះ ជាពិសេសធ្វើឱ្យស្ត្រីទាំងនោះដកខ្លួនឯងចេញពីប្រព័ន្ធយុត្តិធម៌តែម្តង។
- ឧទាហរណ៍៖ ការប្រកាន់ឥរិយាបថជាគ្រួសារ និងចំណងអាពាហ៍ពិពាហ៍បានក្លាយជាសម្ពាធជំរុញអោយស្ត្រីស្វែងរកដំណោះស្រាយតាមរយៈការសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ នៅពេលមានករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង ដែលផ្ទុយទៅនឹងការទទួលបានយុត្តិធម៌ក្នុងព្រហ្មទណ្ឌ។

## ៤. ឧបសគ្គខាងកត្តាផ្សេងៗ

- ស្ត្រីជាច្រើនទទួលការរើសអើងដោយផ្អែកលើយេនឌ័រ ពាក់ព័ន្ធនឹងទម្រង់នៃការរើសអើងផ្សេងទៀតដោយផ្អែកលើកត្តាកំណត់ផ្សេងទៀតដែលបង្ហាញពីស្ថានភាពដែលត្រូវបានគេផាត់ចោល និងមើលរំលង។
- ឧទាហរណ៍៖ ស្ត្រីជនបទមិនត្រឹមតែជួបប្រទះនឹងបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច និងការរស់នៅប្រចាំថ្ងៃដូចជាការចំណាយថវិកា និងពេលវេលាច្រើនក្នុងការធ្វើដំណើរដើម្បីដំណើរការបណ្តឹងនៅតុលាការប៉ុណ្ណោះទេ ថែមទាំងត្រូវមានកាតព្វកិច្ចសម្រាប់គ្រួសារដែលសង្គមបានកំណត់ឱ្យដូចជាការថែទាំកូនចៅជាដើម។



- អ្នកស្រឡាញ់ភេទដូចគ្នាតែងតែយល់ឃើញថាពួកគេស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់នៅពេលដែលព្យាយាមប្រើប្រាស់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ដោយសារតែមានមេធាវីមួយចំនួនតូចប៉ុណ្ណោះដែលផ្តល់សេវាគាំទ្រ និង/ឬ អង្គការសង្គមស៊ីវិលមួយចំនួនតូចដែលផ្តល់ការប្រឹក្សាផ្នែកច្បាប់ដោយឥតគិតថ្លៃទៅក្រុមអ្នកស្រលាញ់ភេទដូចគ្នា។



## ៥. ស្ត្រី និងកុមារីដែលជាប់ពន្ធនាគារ



- ទោះបីជាពុំដឹងអំពីតួលេខជាក់លាក់យ៉ាងណាក៏ដោយ ប៉ុន្តែគិតត្រឹមខែកុម្ភៈ ឆ្នាំ២០២០ នេះ មានពន្ធនាគារចំនួន១៨ ក្នុងចំណោមពន្ធនាគារចំនួន២៨ មានកុមារចំនួន១០៣នាក់កំពុងរស់នៅជាមួយម្តាយរបស់ពួកគេ និងស្ត្រីមានផ្ទៃពោះចំនួន៤៣នាក់ស្ថិតក្នុងការឃុំខ្លួន។
- ប្រព័ន្ធពន្ធនាគារកម្ពុជា មិនមានលទ្ធភាពក្នុងការផ្តល់នូវតម្រូវការចាំបាច់បំផុតសម្រាប់កុមារទេ ដូចជាការអប់រំ ការថែទាំសុខភាព អាហារូបត្ថម្ភ និងប្រព័ន្ធទំនាក់ទំនងសង្គម និងភាពខុសពីស្តង់ដារអន្តរជាតិ។ តុលាការកម្ពុជាមិនបានគិតពីស្ថានភាពជាក់លាក់របស់ស្ត្រីនោះទេ នៅពេលធ្វើការសំរេចចិត្តទាក់ទងនឹងការឃុំឃាំង ដូចជាការមានផ្ទៃពោះជាដើម។

## ការដាក់របាយការណ៍របស់អង្គការសង្គមស៊ីវិលទៅកាន់ក្រុមការងារមុនវគ្គ

របាយការណ៍ស្តីពី "ការទទួលបានយុត្តិធម៌" របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) និងអង្គការទិសដៅយុត្តិធម៌ អាចស្វែងរកតាមរយៈ៖
https://bit.ly/2pkZbIJ



ឧបត្ថម្ភដោយ

EUROPEAN UNION

DCA actalliance

ផលិតដោយ

VOICES for GENDER EQUALITY

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

@CCHRCambodia  @CCHRCambodia  @EU.Cambodia

BY NC SA

ខែមិថុនា ឆ្នាំ២០២០